# បុលៈ កម្ចីដែលមានការប្រាក់ខ្ពស់តាមរយៈសិលាចារឹកសម័យអង្គរ

នៅក្នុងអត្ថបទភាគ១ ស្តីពីការខ្ចីបុលនាសម័យបុរាណតាមរយៈសិលាចារឹក បានបង្ហាញអំពីពាក្យ «ក្តីង» និង «កំដីង» តាមរយៈសិលាចារឹកសម័យមុនអង្គរនិងសម័យកណ្តាល[១] ដើម្បីបង្ហាញអំពីបែបនៃការខ្ចីបុលមួយបែបនាសម័យបុរាណ។ នៅក្នុងអត្ថបទនេះ ជាអត្ថបទបន្តភាគ២ នឹងលើកបន្តអំពីពាក្យ «បុល» មកបង្ហាញតាមរយៈភស្តុតាងក្នុងសិលាចារឹកសម័យអង្គរ ដែលបង្ហាញអំពីរបៀបបុល ការប្រាក់ជាសំណង និងគោលបំណងនៃការបុលទ្រព្យ។

**បុល** គឺជាប្រភេទកម្ចីមានការប្រាក់១០០% ដែលជាទូទៅកំណត់កាលវេលាឬរយៈពេលត្រូវសងគឺ១ឆ្នាំ ឬរយៈពេល១វដ្តរដូវកសិកម្ម។ ក្នុងវចនានុក្រមខ្មែរ ពន្យល់ថា **បុល** គឺបណ្តាក់ទ្វេឬបណ្តាក់មួយជាពីរ គឺបណ្តាក់អ្វីៗមានស្រូវជាដើម កាលដែលយកពីគេមកឬឲ្យទៅគេតែ១ភាគ លុះដល់កាលរដូវ ត្រូវសងឬត្រូវយកវិញជាពីរភាគ[២]។

តាមរយៈសិលាចារឹកប្រាសាទបេងមាលា K.១៥៣ ឆ្នាំ១០០០, សិលាចារឹកវត្តមៀន K.១០៥ ចុងស.វ.ទី១០, សិលាចារឹកប្រាសាទចារ K.២៣៣ ផ្ទាំងខាងជើង ចុងស.វ.ទី១០, និងសិលាចារឹកអូរស្មាច់ ឬសិលាចារឹកវត្តប្រាសាទពជាសំពេង K.១១៩៨ ផ្ទាំងខ ស.វ.ទី១១ សុទ្ធតែបានបង្ហាញអំពីបញ្ហានេះ។ សិលាចារឹកប្រាសាទបេងមាលា K.១៥៣[៣] មានសេចក្តីសំខាន់ផ្តោតលើអំពើបុណ្យរបស់ព្រះគម្តែងអញស្រីសោមេស្វរបណ្ឌិត មានស្រុកនៅឯវ្យាក ជើងសុរេង ស្ថាបនាប្រាសាទព្រះសិវលិង្គ និងថ្វាយដង្វាយផ្សេងៗចំពោះប្រាសាទនោះ។ នៅបន្ទាត់ទី៦ដល់ទី១១ មាននិយាយដល់ការសងដីជំនួសទ្រព្យដែលបានបុលគុណានឹងពីរ។

**សម្រង់សិលាចារឹកប្រាសាទបេងមាលា K.១៥៣**

[…] (៦)… ធ្យរិតោយិ (៧) បក្ទឹមវ្រះអាគ្រមតីរាបិប្វប្រែងានស្រុកាំរាបិ
លេសិតម្រ្វចិចាឆម្វ (៨) លវ្រះអាគ្រមឱយិស្នោដីទ្រៀតពោះនេះហាមឆិបុលិ°
កាងាហាម្វាយ្យ (៩) ដ័ន្ទជ្យដី៤លិដី១០លិដី៥គុណាវ្យរិវ្វោដីតិរម្វាយ្យគុណា

---

[១] សូមអាន៖ https://khmercivilization.ams.com.kh/?p=33390

[២] វចនានុក្រមខ្មែរ, ១ (ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧), ៥៨២។

[៣] សូមអាន៖ https://khmercivilization.ams.com.kh/detail/25181

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

វ្យ៉ាបចន្ទ្យក៉ាន្ទ្យ (១០) ក៉ាយៅ២គុណាយោ៤ ភូមិតិល្ល៉ាគានវ្រះអាឝ្រមតិវាបចិត្ត
ម្វ៉ចិនុវាប្ស (១១) វិត្រែត ម្វ៉ចិនុវាបិប្វូប្រជានស្រុក៉ឱយ៉ស្មោដីត្រាបិតិបុលិ
គុណាវ្យ៉ា° [...]

## *សេចក្តីប្រែសម្រួល*

*ច្បារខាងលិចព្រះអាស្រម វាបបូ ជាប្រធានស្រុក វាបលេស ជាតម្រួតអ្នកបម្រើព្រះអាស្រម ឲ្យជាសំណងទ្រព្យទាំងអស់នេះដែលបានបុល (គឺ) ខ្ទះមួយទម្ងន់៤ជញ្ជីង ១០ តម្លឹង និង៩តម្លឹង គុណជាពីរ រំផ្លោងសិរមួយគុណជាពីរ សម្លៀកស្បៀក២យៅ គុណជា៤យៅ។ ដីទិសឦសានព្រះអាស្រម វាបចិតតម្រួត វាបបពិត្រតម្រួត និងវាបបូប្រធានស្រុក ឲ្យជាសំណងក្របីដែលបានបុលគុណជាពីរ។*

*ចំណែកនៅក្នុងសិលាចារឹកដទៃទៀត ក៏បង្ហាញថា ការបុលទ្រព្យ សត្វពាហនៈ ឬ វត្ថុផ្សេងៗ អាចសងវិញជាវត្ថុទ្រព្យដទៃដែលទំនងជាមានតម្លៃគុណនឹងពីរនៃទ្រព្យដើម។ នៅក្នុងសិលាចារឹកវត្តមៀន[៤] K.១០៥ ចុងស.វ.ទី១០ បង្ហាញថាមានអ្នកបុលក្របីគេ១នឹម យកប្រាក់ទៅជាវថ្មបាយក្រៀមដើម្បីសង់ប្រាសាទ ប៉ុន្តែដោយពុំមានអ្វីសងវិញ និងទំនងជាជាប់បំណុលនោះយូរ ក៏មានព្រះរាជបញ្ជារបស់ព្រះមហាក្សត្រឲ្យកាត់យកស្រែសងថ្លៃជាប់បុលក្របី១នឹមនោះ យកទៅថ្វាយដល់ប្រាសាទព្រះគម្តែងអញក្រកតវតី។ ដូច្នេះ យើងឃើញថាការបុលក្របី១នឹម ត្រូវកាត់វិញដោយស្រែ១ដែលយើងពុំដឹងទំហំច្បាស់ប្រាកដ។ យ៉ាងណាក្តី យើងឃើញថាថ្លៃដែលសងត្រឡប់ទៅវិញ គឺអាចច្រើនជាងក្របី១នឹម គុណជាពីរ ដោយសាររយៈពេលដែលត្រូវសងនោះអូសបន្លាយ។*

## *សម្រង់សិលាចារឹកវត្តមៀន* K.១០៥

[...] (១៧) ៩០៨គកាចតុទ៌្ទតិកោតិភាទ្រូបឧអាជិត្យវារនុមាជិវ្រះគា
សនជ្ជលិ (១៨) វ្រះចាឧជ្ជលិដេជីវ្រះកាម្រតេជីអញ្ញិតវាបិហ្វូឧយតិវបំចាំ
ប្រត្យយជាចត្វារិតិប្រែមោកាឱយ៉ (១៩) ស្រែតវ្រះកាម្រតេជ៌អញ្ញកតវតីតិអំវិ
យស្រែបិឱយ៉ហោតុបុលិត្រាបិយឆ្នាំ១នុទុញ្ញិថ្លោអ្វេជី (២០) នុថ្ងេវ្រះវ្នំមធ្វាប
សិបិខ្ញោញ្ញិផ្ទលិនុឧគាជិក្ខត្តនុប្រត្យយមោកាឱយស្រែថ្វាយ៉ (២១) ត្រាបិ
តិហោតុបិមាជិស្រែវ្រះកាំម្រតេជីអញ្ញិកតវតី [...]

---

[៤] *សូមអានអត្ថបទសិលាចារឹកទី២ នៅក្នុង* https://khmercivilization.ams.com.kh/detail/24853

## សេចក្តីប្រែសម្រួល

(នា)មហាសករាជឆ្នាំ៩០៨ (ថ្ងៃ)ទី១៤កើត ខែភទ្របទ ថ្ងៃអាទិត្យ មានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះគម្តែងអញ (ត្រាស់បង្គាប់)ដល់វាបហឫទ័យសិវ រាជមន្ត្រីប្រចាំការថ្នាក់ទី៤ ប្រើមកថ្វាយស្រែចំពោះព្រះគម្តែងអញភគវតី គឺស្រែដែលត្រូវឱ្យ ដោយហេតុបុលក្របី១នឹម សម្រាប់ទិញថ្មបាយក្រៀមដើម្បីធ្វើប្រាសាទ។ វាបសិបជាខ្ញោញឈ្នួល(មេឈ្នួល) និង(មន្ត្រី)ទសាធិក្រឹត ព្រមទាំងរាជមន្ត្រី (ជាអ្នក)មកឱ្យស្រែ(សង)ថ្លៃក្របី (គឺដី)ស្រែរបស់ព្រះគម្តែងអញភគវតី។

នៅក្នុងសិលាចារឹកប្រាសាទរលំទឹម[៥] K.២៣៣ ស.វ.ទី១០ មានជាភស្តុតាងបញ្ជាក់ថា ការបុលទ្រព្យ អាចសងវិញជាមនុស្ស ប៉ុន្តែមិនបានបង្ហាញនូវលក្ខណៈនិងរយៈពេលត្រូវសងនោះទេ។ ទំនងជារយៈពេលដែលត្រូវសងនោះយូរ និងពុំអាចរកអ្វីសងបាន ទើបយកអ្នកបម្រើទៅកាត់បំណុលនោះទៅវិញ។ សេចក្តីក្នុងសិលាចារឹកនោះបង្ហាញថាមានវាបពៅ ដែលជាទសាធិក្រឹត (អ្នកត្រួតពល១០នាក់?) នៅឯវិជ័យបត្តន បានទៅបុលក្របីមួយក្បាលពីស្តេញក្នុំប្រែង ដើម្បីបង់ពន្ធជូនរាជការ គឺបង់ទៅខ្ញោញស្រូវ។ វាបពៅ បានយកអ្នកបម្រើស្រីម្នាក់ គឺនាង(តៃ)គង្ហីង ទៅសងថ្លៃបុលនោះ។ ត្រង់នេះ ហាក់ឲ្យយើងឆ្ងល់ដែរថា ការបុល ជាធម្មតា ត្រូវសងគុណនឹងពីរ ដែលយ៉ាងណាក្តី ថ្លៃសងជាក្របី២ក្បាល និងមនុស្សម្នាក់ហាក់មានតម្លៃខុសគ្នាយ៉ាងឆ្ងាយ។ យ៉ាងនេះក្តី យើងមិនយល់លក្ខណៈលម្អិតនៃការបុលនោះឡើយ។ម្យ៉ាងវិញទៀត សិលាចារឹកនេះ ក៏បង្ហាញដែលថា ការបង់ពន្ធផ្នែកកសិកម្ម គឺត្រូវបង់ជាផលកសិកម្ម ឬសត្វពាហនៈ ពុំអាចបង់ជាមនុស្សបាននោះទេ។ ហេតុដូច្នេះហើយ ទើបយើងឃើញថា វាបពៅ មានអ្នកបម្រើស្រីម្នាក់ មិនអាចកាត់កងបង់ពន្ធបាននោះទេ ទើបត្រូវទៅបុលក្របី ដើម្បីបង់ពន្ធនោះជូនរាជការ្យ។

---

[៥] George Cœdès, 'La stèle du Tûol Rolom Tim: Essai d'interprétation par la langue bahnar d'un texte juridique khmer du Xème siècle', *Journal Asiatique* 242, no. 1 (1954): 49–67.

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## សម្រង់សិលាចារឹកប្រាសាទរលំទឹម K.២៣៣

[...] មនិវាបិពៅឧតាជិក្ងុតវិជ (១៥) យបត្តនទៅបុលិក្រាបិម្វាយត ស្តេញ្ញីរ៎ទ្រេង៑ ◦ ឱយិវ្រ៑ះរាជកាយ៌្យតខ្ញា (១៦) ញ៑ស្រូ◦វាបិពៅយោគិតែក ធិហ្សង៑ឱយិថ្វាយតស្តេញ្ញីរ៎ទ្រេង៑ ◦ យោ (១៧) គិតែកធិហ្សង៑ថ្វន្តវ្រ៑ះកម្រ តេង៑អញ្ញគិរបត្តន្ទ◦តិឧក្តប្រិកស្ត ◦ [...]

## សេចក្តីប្រែសម្រួល

មានវាបពៅ(ជា)ទសាធិក្រី(នៅ)វិជ័យបត្តន ទៅបុលក្របីមួយ(ក្បាល) ពីស្តេញក្នុំប្រែង (ដើម្បី)ឲ្យព្រះរាជការ្យដែលជាខ្ញោញស្រូវ។ វាបពៅ យកតែគង្ហីង (តែកនហ្សង[៦])ឲ្យជាថ្លៃ(បុលសង)ដល់ស្តេញក្នុំប្រែង។ (ក៏)យកតែគង្ហីងថ្វាយប្រាសាទព្រះកម្តេងអញសិវបត្តន (និង)ចារទុកក្នុងសិលាចារឹក។

ការបុលទ្រព្យ កាលបើមិនសងវិញ គឺម្ចាស់បំណុលត្រូវប្តឹងឡើងទៅតុលាការ ដើម្បីដោះស្រាយក្តី។ ក្នុងករណីគ្មានទ្រព្យដើម្បីសង នឹងត្រូវរឹបអូសឬកាត់ដីធ្លីសងបំណុលនោះ។ សេចក្តីនេះ មាននៅក្នុងសិលាចារឹកប្រាសាទចារ[៧] K.២៥៧ ផ្ទាំងខាងជើង ចារក្នុង ស.វ.ទី១១។ សិលាចារឹកនេះ បង្ហាញសេចក្តីសំខាន់ គឺដីនៅឯគម្រ្យាងដែលម្រតាញខ្ញោញស្រីនរបតិវីរវម្ម៌ នាំអ្នកពាក់ព័ន្ធនឹងការបុលពុំសង ចូលតុលាការដើម្បីជម្រះក្តី ហើយគេក៏កាត់យកស្រែនោះសងថ្លៃបំណុល។ ដើមហេតុគឺ វាបវិត ជាខ្ញោញឈ្នួលអ្នកប្រដាល់ បានបុលប្រាក់ទម្ងន់មួយជញ្ជីង ចូរៅទិ១ទម្ងន់៦ជញ្ជីង សម្លៀក១០យោ ពីម្រតាញស្រីនរបតីវីរវម្ម៌ដើម្បីទិញសំណង់អ្វីមួយ។ លុះដល់ឆ្នាំត្រូវសង សភាកាត់ក្តីឲ្យ កំរែវលំឡូន សងទ្រព្យទាំងនោះគុណនឹងពីរ។ ដោយសារមិនមានទ្រព្យសង ទើប វាបវិត និងវាបទន ជាប្រធានស្រុកគម្រ្យាង វាបតនជាខ្ញោញឈ្នួលអ្នកប្រដាល់ វាបគោជាមេ វាបទនជាមេ វាបអ្យក ជាមេអ្នកប្រដល់ស្រុកគម្រ្យាង កាត់ដីគម្រ្យាងឲ្យទៅម្រតាញខ្ញោញស្រីនរបតិវីរវម្ម៌ជាថ្លៃសងបំណុងប្រាក់ ទ្រព្យ និងសម្លៀកដែលបានបុលគុណជាពីរ។

---

[៦] សូមអានបន្ថែមអំពីពាក្យ «កនិហ្សង» និង «គង្ហីង»៖ https://khmercivilization.ams.com.kh/detail/2863

[៧] George Cœdès, *Inscriptions du Cambodge*, EFEO, Collection de textes et documents sur l’Indochine, III (Editions de Boccard., 1952), 4:140–50.

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

## សម្រង់សិលាចារឹកប្រាសាទចារ K.២៨៧ ផ្ទាំងខាងជើង

[...] (១) ... មាគ៌្គឝិរវ្ឫហស្បតិវារនុម្រតាញិខ្លោញិឝ្រីនរបតិវីរវម៌្មប្រែ (២) ...យិតកន្ទ្វាយិម្រតាញិខ្លោញិនាំវាបិទនិមុឞ្ដិយុទ្ធតមានិ (៣)... វាបិឥនិខ្លោញិផ្ទាលិមុឞ្ដិយុទ្ធ◦វាបិគោមូល◦វាបិគាបិមូល◦វាបិទនិមូលវា (៤) [បិ អ្យកិ] មូលមុឞ្ដិយុទ្ធស្រុកិកម្ប្យាងីមោកិវ្រះសភា◦កាថាមនិវាបិវិតិខ្លោញផ្ទាលិមុឞ្ដិ (៥) [យុទ្ធ] បុលិប្រាកិជ្យងីម្វាយិវោជិម្វាយិជ័និជ្យងីប្រម្វាយិចន្ល្យាកិយោតប្បតម្រតាញិខ្លោញ (៦) ឝ្រីនរបតិវីរវម៌្មនុទុញ----មណ្ឌីរកាលតតិឆ្នាំស្រចិនិល្ណ៌្ហយកាំរៃលំទ្យនិល្វោះគុណា (៧) ទ្រវ្យតពោះហា◦អ្យតិទ្រវ្យនេបិវាបិវិតិវាបិទនិប្រធានស្រុកិកម្ប្យាងី◦វាបិឥនិខ្លោញិ (៨) [ផ្ទាលិមុឞ្ដិ]យុទ្ធវាបិគោមូលវាបិគាបិមូលវាបិទនិមូលវាបិអ្យកិមូលមុឞ្ដិយុទ្ធស្រុកិកម្ប្យា (៩) ងី---ភូមិកម្ប្យាងី-------ឱយិតម្រតាញិខ្លោញិឝ្រីនរបតិវីរវម៌្មថ្វាយិប្រាកិនុ (១០) ទ្រវ្យនុចន្ល្យាកិតគុណា---- [...]

## សេចក្ដីប្រែសម្រួល

(អត្ថបទដាច់) ខែមិគសិរ ថ្ងៃព្រហស្បតិ៍ នូវម្រតាញខ្លោញស្រីនរបតិវីរវម៌្មប្រើ --- ដែលជាក្មួយរបស់ម្រតាញខ្លោញ ឲ្យនាំវាបទនអ្នកប្រដាល់ដែលមាន --- វាបឥតខ្លោញឈ្នួលអ្នកប្រដាល់ វាបគោជាមេ វាបគាបជាមេ វាបទនជាមេ វាបអ្យក ជាមេអ្នកប្រដាល់ស្រុកគម្ប្យាងមកកាន់ព្រះសភា(តុលាការ)។ (លោក)រៀបរាប់ថា វាបវិតខ្លោញឈ្នួលអ្នកប្រដាល់ បានបុលប្រាក់ទម្ងន់៦ជញ្ជីង ចូវោទិមួយទម្ងន់៦ជញ្ជីង សម្លៀក១០យៅ ពីម្រតាញខ្លោញស្រីនរបតិវីរវម៌្មដើម្បីទិញ---មន្ទីរ។ កាលដល់ឆ្នាំ(ត្រូវសង)ស្រេច (តុលាការ)កាត់ក្ដីឲ្យកំរៃលំឡៀន សងទ្រព្យទាំងនោះគុណនឹងពីរ។ ឥតទ្រព្យសង ទើបវាបវិត វាបទន ជាប្រធានស្រុកគម្ប្យាង វាបឥតជាខ្លោញឈ្នួលអ្នកប្រដាល់ វាបគោជាមេ វាបគាបជាមេ វាបទនជាមេ វាបអ្យកជាមេអ្នកប្រដាល់ស្រុកគម្ប្យាង---ដីគម្ប្យាង---ឲ្យដល់ម្រតាញខ្លោញស្រីនរបតិវីរវម៌្មជាថ្លៃសងប្រាក់ ទ្រព្យ និងសម្លៀកដែលត្រូវសងគុណជាពីរ...។

អត្ថបទដោយៈ ហ៊ិន ឈុនតេង

*សិលាចារឹកអូរស្នាច់ ឬសិលាចារឹកវត្តប្រាសាទរាជាសំរោង[៨] K.១១៩៨ ផ្ទាំង២ ស.វ. ទី១១ ក៏មានបង្ហាញអំពីការកាត់ដីសងជំនួសទ្រព្យដែលបានបុលដែរ។ សេចក្តី គឺមានវាប លេ ជាមានភូមិ១០ ជាអ្នករក្សាព្រះវសន(សម្លៀកបំពាក់ព្រះ) នៅស្រុកត្រាចបានបុលមាស ធ្លិន២តម្លឹងពីព្រះកំស្តេងអញស្រីលក្ស្មីបតិវម៌្មដើម្បី(បង់ពន្ធ)ឲ្យរាជការ ត្រូវសងជាមាសទ្វេគុណជា៤តម្លឹង ហើយឥតមានមាសដើម្បីសងវិញ ក៏ឲ្យដីនៅឯត្រាចជាថ្លៃសំណងវិញ។*

***សម្រង់សិលាចារឹកអូរស្នាច់ឬវត្តប្រាសាទរាជាសំរោង K.១១៩៨ ផ្ទាំង២***

[...] (២៧)... ៩៣៤ឝកកាមឞិវាបិលេឞគ្រោមឞ្នក្តិវ្រះវសឞស្រុកិត្រា (២៨) ចិបុលិមាសធ្លិឞិលិជី២តវ្រះកំស្តេជីអញគ្រីលក្ស្មីបតិវម៌្មបិឱយរាជកាយ៌្យមឞិគុណាមាសិលិជី៤បិអ្យតិមាសិបិឱយឱយិភូមិអាយិត្រាច... [...]

***សេចក្តីប្រែសម្រួល***

*មហាសករាជឆ្នាំ៩៣៤ មានវាបលេទសគ្រាមជាអ្នករក្សាព្រះវសន នៅស្រុកត្រាចបុលមាសធ្លិន២តម្លឹងពីព្រះកំស្តេងអញស្រីលក្ស្មីបតីវម៌្មដើម្បី (បង់ពន្ធ)ឲ្យរាជការ ត្រូវសងមាសគុណជា៤តម្លឹង (ដោយ)មិនមានមាស ដើម្បីសង ឲ្យដីនៅឯត្រាច(ជាសំណងវិញ)។*

*ការបុលទ្រព្យ តាមរយៈសិលាចារឹកសម័យអង្គរ មានគោលដៅសំខាន់២យ៉ាង គឺការធ្វើបុណ្យ និងការបង់ពន្ធជូនរាជការ។ សិលាចារឹកដែលបានដកស្រង់មកបង្ហាញខាងលើជាសក្ខីភាពរួចទៅហើយ តែនៅទីនេះ នឹងលើកយកសិលាចារឹកវត្តដំណាក់[៩] K.៤២០ ដើម្បីបង្ហាញពីការបុលទ្រព្យដើម្បីជាវដីថ្វាយប្រាសាទបន្ថែម។ ម្ចាស់បំណុលសំខាន់ដែលមានទ្រព្យសម្រាប់អ្នកផងបុល នៅក្នុងសិលាចារឹកនេះ គឺព្រះគម្តែងអញនៅឯព្រេច។ ដីទី១ គឺដីចំណាត់អង្គ តម្រួតពលខ្ញោញគាប ឲ្យថ្លៃដីជាដំរី១ ចូវៅទិ កន្ទោរស្តោះ ភាជន៍១០ ដែលបុលពីព្រះគម្តែងអញអាយព្រេច។ ដីទី២ គឺដីចំណាត់ជើង កំស្តេងលំវាង ឲ្យថ្លៃដីជា ចូវៅទិ កន្ទោរស្តោះ សរុបទម្ងន់៧ជញ្ជីង ដែលបុលពីព្រះគម្តែងអញអាយព្រេចកាលពីធ្វើ*

[៨] Chhom Kunthea et al., ‘Stela from Vat Samrong (K. 1198)’, accessed 10 December 2025, https://dharmalekha.info/texts/INSCIK01198.

[៩] Cœdès, *Inscriptions du Cambodge*, 4:161–66.

*បុណ្យធ្វងព្រះទំនប់។ ដីទី៣ គឺដីចំណាត់ព្រៃមួយ ដែលកំស្តេងផ្ទូរខ្ពលឲ្យសំណងជាអង្គររាជការ្យនៅឯលោង និងថូវៅទិ កន្ទោរស្តោះ ៦ ស្មើទម្ងន់៧ជញ្ជីង ដែលបានបុលពីព្រះគម្តែងអញអាយព្រេច។ ដីទី៤ គឺព្រៃព្រះភាគ ឲ្យថ្លៃដីជាមាស១០តម្លឹង ដែលបានបុលពីព្រះគម្តែងអញអាយព្រេច។ ដីទាំងអស់នេះ គឺជាវដើម្បីចូលរួមជាមួយព្រះគម្តែងអញស្រីវីរេន្ទ្រវម្ម៌ ដើម្បីថ្វាយទៅប្រាសាទ។*

## *សេចក្តីសរុប*

*សរុបរួមមក **បុល** គឺជាការខ្ចីទ្រព្យរបស់ដោយកំណត់ការប្រាក់១០០ភាគរយ គឺពេលខ្ចី១ ត្រូវសងគុណជា២។ ការសងវិញ អាចសងជាទ្រព្យដែលខ្ចី ឬទ្រព្យដែលមានតម្លៃស្មើ ឬក៏ជាអ្នកបម្រើ។ ការពុំទូរទាត់សងបំណុលតាមការកំណត់ ម្ចាស់បំណុលអាចប្តឹងឡើងតុលាការដើម្បីជម្រះក្តីបាន។ កាលបើពុំមានទ្រព្យរបស់សងវិញ អ្នកជំពាក់បំណុល អាចកាត់ដីដែលមានតម្លៃស្មើនឹងសំណងសងវិញបាន។ ការបុលទ្រព្យពីសម័យអង្គរ ដើម្បីបំណង២សំខាន់ គឺបង់ពន្ធជូនរាជការ្យ និងជាវដីធ្លីឬសម្ភារៈសំណង់ដូចជាថ្មបាយក្រៀមជាដើម ថ្វាយប្រាសាទ។*

## *បញ្ជីឯកសារ*

*វចនានុក្រមខ្មែរ. ១. ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧។*

Cœdès, George. *Inscriptions du Cambodge*. EFEO. Vol. 4. Collection de textes et documents sur l’Indochine, III. Editions de Boccard., 1952.

Cœdès, George. ‘La stèle du Tûol Rolom Tim: Essai d’interprétation par la langue bahnar d’un texte juridique khmer du Xème siècle’. *Journal Asiatique* 242, no. 1 (1954): 49–67.

Kunthea, Chhom, Pou Saveros, Gerschheimer Gardi, Griffiths Arlo, and Soutif Dominique. ‘Stela from Vat Samrong (K. 1198)’. Accessed 10 December 2025. https://dharmalekha.info/texts/INSCIK01198.

*អត្ថបទដោយ៖ ហ៊ុន ឈុនតេង*

## បញ្ជីរូបភាព

### សម្រង់សិលាចារឹកប្រាសាទលំងឹម K.២៣៣



(១៤) [...] មនិវាបិរៅឧតាជិក្ខតវិជ
(១៥) យបត្តនដៅបុលិក្រាបិម្វាយតស្តេញ្ញ៉ុំច្រៃង៑ ៚ ឱយិប្រែះរាជកាយ៌្យតខ្ញោ
(១៦) ញស្រូ៎ះវាបិរៅយោកិតែកនិហ្យង៑ឱយិថ្វាយតស្តេញ្ញ៉ុំច្រៃង៑ ៚ យោ
(១៧) កិតែកនិហ្យង៑ថ្វុន្តប្រែះកម្រតេង៑អញ្ញកិវបត្តន្ទះតិទុក្កប្រែកស្ត ៚ [...]

វាបរៅ(ជា)ទសាធិក្រី(នៅ)វិជ័យបត្តន ទៅបុលក្របីមួយ(ក្បាល)ពីស្តេញក្នុំច្រៃង (ដើម្បី)ឲ្យព្រះរាជការ្យដែលជាខ្ញោញស្រូវ។ វាបរៅ យកតែគង្ហីង (តែកនហ្យង)ឲ្យជាថ្លៃ(បុលសង)ដល់ស្តេញក្នុំច្រៃង។ (ក៏)យកតែគង្ហីងថ្វាយប្រាសាទព្រះគម្តែងអញសិវបត្តន (និង)ចារទុកក្នុងសិលាចារឹក។

### សម្រង់សិលាចារឹកវត្តមៀន K.១០៤



(១៧) ៩០៨តកាចតុទ្ទ៌តិកោតិកាទ្រិបឧអាទិត្យវារឆុមានិប្រែះគាសនធូលិ
(១៨) ប្រែះចានធូលិជេង៑ប្រែះកម្រតេង៑អញ្ញតវាបិហ្វនយតិវបំចាំប្រិត្យយជាចត្វារិតិប្រែមោកឱយិ
(១៩) ស្រែតប្រែះកម្រតេង៑អញ្ញភគវតីតិអំវិយស្រែបិឱយិហេតុបុលិក្រាបិយន្ទ៌្យ១ឆុទុញ្ញថ្មោរេង៑
(២០) ឆុថ្ងៃប្រែះវ្នំមធ្វាបសិបិខ្ញោញជ្ឈលិឆុឧតាជិក្ខត្តឆុប្រិត្យយមោកឱយស្រែថ្វាយិ
(២១) ក្រាបិតិហេតុបិមានិស្រែប្រែះកំម្រតេង៑អញ្ញភគវតី [...]

(នា)មហាសករាជឆ្នាំ៩០៨ (ថ្ងៃ)ទី១២កើត ខែភទ្របទ ថ្ងៃអាទិត្យ មានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះគម្តែងអញ(ត្រាស់បង្គាប់)ដល់វាបហឫទ័យសិវ រាជមន្ត្រីប្រចាំការថ្នាក់ទី៤ ប្រើមកថ្វាយស្រែចំពោះព្រះគម្តែងអញភគវតី គឺស្រែដែលត្រូវឱ្យដោយហេតុបុលក្របី១នឹម សម្រាប់ទិញថ្មបាយក្រៀមដើម្បីធ្វើប្រាសាទ។ វាបសិបជាខ្ញោញឈ្នួល(មេឈ្នួល) និង(មន្ត្រី)ទសាធិក្រឹតព្រមទាំងរាជមន្ត្រី (ជាអ្នក)មកឱ្យស្រែ(សង)ថ្លៃក្របី (គឺដី)ស្រែរបស់ព្រះគម្តែងអញភគវតី។

### សម្រង់សិលាចារឹកអូរស្មាច់ ឬវត្តប្រាសាទរាជាសំពោង K.១១៩៨



(២៧) ... ៩៣៤តកាមនិវាបិលេឧតគ្រាមធ្មកិប្រែះវសនស្រុកិត្រា
(២៨) ចិបុលិមាសិឆ្តិនិលិជ៑២តប្រែះ[កំ]ស្តេង៑អញត្រីលក្ស្មិបតិវម្ម៌បិឱយិរាជកាយ៌្យមនិគុណាមាសិលិជ៑៤បិអ្យតិមាសិបិឱយឱយិភូមិអាយិត្រាចិ... [...]

មហាសករាជឆ្នាំ៩៣៤ មានវាបលេទសគ្រាមជាអ្នករក្សាព្រះវសននៅស្រុកត្រាចបុលមាសឆ្ទិន២តម្លឹងពីព្រះកំស្តេងអញស្រីលក្ស្មីបតីវម្ម័ដើម្បី(បង់ពន្ធ)ឲ្យរាជការ ត្រូវសងមាសគុណជា៤តម្លឹង (ដោយ)មិនមានមាសដើម្បីសង ឲ្យដីនៅឯត្រាច(ជាសំណង)វិញ។

អត្ថបទដោយៈ ហ៊ិន ឈុនតេង